ព្រឹត្តិបត្របច្ចេកទេសលេខ ៨០

# វិធានការចម្រុះការពារដំណាំ - ដំណាំអន្ទាក់

## តើដំណាំអន្ទាក់គឺជាអ្វី ?



ដំណាំអន្ទាក់ គឺជាប្រភេទដំណាំស្មៅដែលគេដាំព័ទ្ធជុំវិញដំណាំមួយ ដើម្បីខ័ណ្ឌវាអោយនៅដាច់ដោយឡែកពីបណ្តារុក្ខជាតិ ឬដំណាំមួយចំនួនទៀតដែលដុះនៅក្បែរគ្នា ដែលអាចជាប្រភពចម្លងនូវជម្ងឺវីរុស និងកត្តាចង្រៃដ៏ទៃទៀតមកលើដំណាំ។

គោលបំណងសំខាន់របស់ដំណាំអន្ទាក់ គឺដើម្បីការពារការចម្លង ជម្ងឺវីរុស ចេញពីដំណាំមួយចំនួនតាមរយៈពពួកចៃ ហើយក៏មានករណីខ្លះ ចម្លងតាមរយៈពពួកមមាចជញ្ជក់ស្លឹកផងដែរ ។ នៅពេលដែលពពួកសត្វល្អិតទាំងនេះបានជញ្ជក់យករុក្ខរសរបស់រុក្ខជាតិមានជម្ងឺ វាបាននាំយកមកជាមួយ នូវមេរោគជម្ងឺវីរុសដែលនៅជាប់ផ្នែកខាងក្រៅមាត់របស់វា (ម្ជុលបឺត) ហើយនៅដែលពេលវាចុចទៅលើដំណាំស្លឹកធំមួយចំនួន វានឹងចម្លងមេរោគទៅអោយដំណាំនោះភ្លាម ដូច្នេះដំណាំអន្ទាក់ដើរតួនាទីជាដំណាំជួរមុខ ក្នុងការការពារដំណាំនៅពេលដែលសត្វល្អិតមកដល់ វាត្រូវតោងជាប់និងចុចជញ្ជក់លើដំណាំអន្ទាក់មុនគេ ដែលជាហេតុធ្វើអោយមាត់របស់វាត្រូវបានលាងសម្អាតមុននឹងចូលទៅចុចជញ្ជក់ដំណាំដែលការពារ ។ ពពួកដំណាំស្មៅមួយចំនួនដូចជា អំពៅ ស្មៅចំណីសត្វ ស្រូវមីឡេ ស្គួយ (ស្មៅចំណីសត្វមានគ្រាប់) និងពោត គឺជាប្រភេទដំណាំអន្ទាក់ដែលគេនិយមដាំដុះជាងគេ ដោយសារវាជាដំណាំដែលមានកម្ពស់ខ្ពស់ និងងាយស្រួលដាំដុះ ។

ដំណាំអន្ទាក់ មានតួនាទីបន្ថែមទៀត គឺជារុក្ខជាតិរបាំងជួយការពារដំណាំ ពីខ្យល់ខ្លាំង ធូលី និងអាចជួយថែរក្សាសត្រូវធម្មជាតិ ដូចជា ពពួកសត្វអណ្តើកមាស និងសត្វកណ្តូបបុកស្រូវ ។

## តើដំណាំអន្ទាក់ត្រូវមានលក្ខណៈសំខាន់ៗអ្វីខ្លះ ដែលអាចជួយការពារដំណាំ កុំអោយឆ្លងជម្ងឺវីរុសបាន?



1. ដំណាំអន្ទាក់ត្រូវខ្ពស់ជាងដំណាំដែលយើងចង់ការពារ ដូច្នេះគេត្រូវដាំវាឲ្យបានមុនដំណាំ ។ ជាទូទៅដំណាំអន្ទាក់ត្រូវដាំពី ៣ ទៅ ៤សប្តាហ៍ មុនដំណាំដែលចង់ការពារ ។

2. ដើម្បីការពារក្រុមដំណាំ អំបូរត្រសក់ និង អំបូរស្វាយចន្ទីឡាណាសេ (ត្រប់ ម្ទេស ប៉េងប៉ោះ) កុំឲ្យឆ្លងជម្ងឺវីរុស គេត្រូវដាំដំណាំអន្ទាក់ដូចជា ពោត ស្គួយ អំពៅ ស្មៅដែលខ្ពស់ ឬ ពពួកឬស្សីទាប ដើម្បីការពារ ។





3. ត្រូវដាំដំណាំអន្ទាក់នៅជុំវិញចម្ការ ដើម្បីការពារកត្តាចង្រៃមិនឲ្យមានលទ្ធភាពចូលទៅដល់ចម្ការបាន ១00% ។

4. ដំណាំអន្ទាក់ត្រូវក្រាស់ល្មម (យ៉ាងហោចឲ្យបាន ៣ជួរ ក្នុងករណីជាដំណាំពោត) ដើម្បីការពារភ្នាក់ងារចម្លងរោគពីការឆ្លងកាត់ដោយផ្ទាល់ទៅកាន់ដំណាំ ។

5. ដើម្បីជៀសវាងពីការចម្លងរោគបណ្តាលមកពីជម្ងឺវីរុស មិនត្រូវអោយមានពពួកស្មៅស្លឹកធំនៅក្នុងដំណាំអន្ទាក់ដូចគ្នា ដែលជាហេតុបង្កឲ្យជម្ងឺវីរុសមានការសាយភាយ ។

6. ត្រូវដាក់ជីស្រោចស្រពដំណាំអន្ទាក់អោយបានត្រឹមត្រូវ ដើម្បីអោយមានពណ៌បៃតងស្រស់ ដែលអាចជួយទាក់ទាញពពួកចៃចូលមកទំ ។

7. ត្រូវថែរក្សាដំណាំអន្ទាក់កុំឲ្យមានកត្តាចង្រៃ និង ជម្ងឺដូចជា ពពួកជម្ងឺផ្សិត ចៃពោត កណ្ដៀរពោត និងដង្កូវ ដើម្បីការពារកត្តាចង្រៃកកើតឡើងវិញក្នុងដីដាំដំណាំ ៕

**កម្ពុជាហាវ៉េស**
ផ្ទះលេខ ៤៦ ផ្លូវ ៣១០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន
ក្រុងភ្នំពេញ
ទូរស័ព្ទ ០២៣ ៩៩៦ ៤១៩
harvest@fintrac.com

ព្រឹត្តិបត្រនេះរៀបចំឡើងក្រោមការឧបត្ថម្ភពីប្រជាពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)។

ខ្លឹមសារនៅក្នុងឯកសារនេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុន ហ្វីនត្រាក់ Fintrac Inc. និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬ រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។